# ព្រះរាជក្រម

នស/រកម/០៩២៥/០៣០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



Scanned with CamScanner

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Scanned with CamScanner

**មាត្រាមួយ ._**

មាត្រា១ មាត្រា៧ មាត្រា១៦ មាត្រា២៧ មាត្រា២៨ មាត្រា២៩ និងមាត្រា៣៤ នៃច្បាប់ស្តីពីសញ្ជាតិ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា១ ._ ថ្មី**

ច្បាប់នេះមានគោលបំណងជានាការអនុវត្តដែនយុត្តាធិការរបស់ព្រះរាជាណាចក្រកម្ពុជា ទៅលើរូបវន្តបុគ្គល ដើម្បីកំណត់អំពីការទទួលបានសញ្ជាតិខ្មែរ ព្រមទាំងការបាត់សញ្ជាតិខ្មែរតាមរយៈការលះបង់សញ្ជាតិខ្មែរនិងការដកសញ្ជាតិខ្មែរ ចំពោះជនដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និងដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ។

**មាត្រា៧ ._ ថ្មី**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបាននិរទេសឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក។

**មាត្រា១៦ ._ ថ្មី**

ជនដែលត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។ ខ្លឹមសារនៃសម្បថ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ។

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ជូនបន្ទាប់ពីបានបំពេញរួចរាល់នូវនីតិវិធីនៃការធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

**មាត្រា២៧ ._ ថ្មី**

ជនដែលត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវធ្វើសម្បថនៅចំពោះមុខតុលាកាកំពូល។ ខ្លឹមសារនៃសម្បថ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ។

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ជូនបន្ទាប់ពីបានបំពេញរួចរាល់នូវនីតិវិធីនៃការធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

**មាត្រា២៨ ._ ថ្មី**

ប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨(ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបានដោយស្ម័គ្រចិត្ត ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត។

ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ប្រជាពលរដ្ឋខ្មែរជាម្តាយឬឪពុក ដែលមានកូនជាអនីតិជន។

បែបបទនិងនីតិវិធីនៃការសុំលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា២៩ ... ថ្មី**

ប្រជាពលរដ្ឋខ្មែរអាចត្រូវបានដកសញ្ជាតិខ្មែរ ក្នុងករណីណាមួយ ដូចខាងក្រោម៖

១- ប្រព្រឹត្តអំពើក្បត់ជាតិ ឬធ្វើសកម្មភាពឃុបឃិតគ្នាជាមួយបរទេស ដែលនាំឱ្យអន្តរាយដល់ផលប្រយោជន៍ស្នូលរបស់ព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើសកម្មភាពដែលនាំឱ្យអន្តរាយដល់អធិបតេយ្យជាតិ បូរណភាពទឹកដី និងសន្តិសុខជាតិ។

៣- ចូលបម្រើកងទ័ពនៃរដ្ឋបរទេសដោយស្ម័គ្រចិត្ត ឬបំពេញតួនាទីជាមន្ត្រីសាធារណៈនៃរដ្ឋបរទេស និងមិនព្រមលាឈប់ ទោះបីមានបញ្ជាពីរាជរដ្ឋាភិបាលកម្ពុជា។

៤- បានទទួលសញ្ជាតិខ្មែរដោយការក្លែងបន្លំ ឬការផ្តល់ព័ត៌មានមិនពិត។

៥- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលពាក់ព័ន្ធនឹងការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ឬអំពើភេរវកម្ម។

ការដកសញ្ជាតិខ្មែរពីកំណើតអាចធ្វើទៅបាន លុះត្រាតែប្រជាពលរដ្ឋខ្មែររូបនោះមានអាយុ១៨(ដប់ប្រាំបី)ឆ្នាំយ៉ាងតិច និងមានសញ្ជាតិមួយផ្សេងទៀត ឬមានមូលដ្ឋានដែលអាចជឿជាក់ថា ប្រជាពលរដ្ឋខ្មែររូបនោះអាចទទួលបានសញ្ជាតិផ្សេងទៀត ឬទទួលបានការគាំពារពីរដ្ឋបរទេស។ ការដកសញ្ជាតិខ្មែរពីកំណើត ត្រូវធ្វើឡើងបន្ទាប់ពីទទួលបានយោបល់ពីគណៈកម្មការជាតិមួយ ដែលការបង្កើតនិងដំណើរការគណៈកម្មការជាតិនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បែបបទនិងនីតិវិធីនៃការដកសញ្ជាតិខ្មែរ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការដកសញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។

**មាត្រា៣៤ ... ថ្មី**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

**មាត្រាពីរ ...**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ១៣ កើត ខែ ភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០២៥

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់**

**ប្រមុខរដ្ឋស្តីទី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ពរសៈ. ២៥០៩. ១២០៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

អភិសន្តិបណ្ឌិត **ស សុខា**

# ឧបសម្ព័ន្ធ

## ខ្លឹមសារនៃសម្បថ
## សម្រាប់ជនដែលត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរ
## ដោយអាពាហ៍ពិពាហ៍ និងដោយសញ្ជាតូបនីយកម្ម

ខ្លឹមសារនៃសម្បថមានអត្ថន័យដូចតទៅ៖

"ខ្ញុំសូមសច្ចាជាឱឡារិកថា ខ្ញុំមានភក្តីភាព និងសេចក្តីស្នេហាចំពោះជាតិ និងមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត។

ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការការពារឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត។"

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL